ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង
ក្រុមលទ្ធកម្ម
លេខ : ០៤៩...............កល.អយកខ.សត

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
# ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលៈ
## ១-អគារសាលប្រជុំជាន់ផ្ទាល់ដីមន្ទីរអប់រំយុវជននិងកីឡាខេត្តស្ទឹងត្រែង
## ២-ក្លោងទ្វារ និងរបងពីមុខ វិទ្យាល័យព្រះរាជបូជនីយកិច្ច
## ៣-អគារជាន់ផ្ទាល់ដីការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្ទឹងត្រែង
## ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុលៈ ១-អគារសាលប្រជុំជាន់ផ្ទាល់ដីមន្ទីរអប់រំយុវជននិងកីឡាខេត្តស្ទឹងត្រែង(ទំហំ ១៦ម៉ែត្រx៣៣,៨០ម៉ែត្រ=៥៤០,៨០ម៉ែត្រការ៉េ) ២-ក្លោងទ្វារ និងរបងពីមុខ វិទ្យាល័យព្រះរាជបូជនីយកិច្ច(ទំហំក្លោងទ្វារប្រឡោះ ៥ម៉ែត្រ កម្ពស់ ៦,២០ម៉ែត្រ របងកម្ពស់ ២,៤០ម៉ែត្រ ប្រវែង ៣២០ម៉ែត្រ) ៣-អគារជាន់ផ្ទាល់ដីការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្ទឹងត្រែង(ទំហំសរុប ៨៨,៥០ម៉ែត្រការ៉េ) ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង ដែលមានអាសយដ្ឋានភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ចាប់ពីថ្ងៃទី ២០...... ខែ មិថុនា.....ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៧៤ ២១០ ៤២៧) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង០៨:៣០ថ្ងៃទី២១...... ខែ.កក្កដា.....ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៨:៣០. ថ្ងៃទី ២១...... ខែ កក្កដា........ ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅស្ទឹងត្រែង ថ្ងៃទី .១៩..... ខែ មិថុនា ឆ្នាំ២០១៧

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង**
**និងជាប្រធានក្រុមលទ្ធកម្ម**

ហ៊ាង ប៊ុំលី

ចម្លងជូន ៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ